APHR ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# សមាជិកសភាអាស៊ាន ថ្កោលទោសចំពោះសេចក្តីស្នើច្បាប់ស្តីពីគណបក្សនយោបាយ ដោយចាត់ទុកថាជា "ការស្លាប់នៃលទ្ធិប្រជាធិបតេយ្យ" នៅក្នុងប្រទេសកម្ពុជា

ទីក្រុងចាកាតា ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៧ - នៅថ្ងៃនេះ សមាជិកសភា មកពីជុំវិញតំបន់អាស៊ីអាគ្នេយ៍ បានថ្កោលទោសចំពោះការខិតខំប្រឹងប្រែងរបស់គណបក្សកាន់អំណាច នៅក្នុងប្រទេសកម្ពុជា ក្នុងការធ្វើច្បាប់យ៉ាងប្រញាប់ប្រញាល់ ដែលមានបំណងសំដៅដល់គណបក្សប្រឆាំង និង អំពាវនាវដល់អង្គអន្តរជាតិ និងតំបន់ឱ្យធ្វើការថ្កោលទោសចំពោះការផ្លាស់ប្តូរនេះ។

អង្គការសមាជិកសភាអាស៊ាន ដើម្បីសិទ្ធិមនុស្ស ព្រមានថា សេចក្តីស្នើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ ដែលធ្វើឡើងដោយគណបក្សកាន់អំណាចក្នុងសប្តាហ៍នេះ នឹងបង្កើតឱ្យមាននូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។

ឯកឧត្តម Charles Santiago ប្រធានអង្គការសមាជិកសភាអាស៊ាន ដើម្បីសិទ្ធិមនុស្ស និងជាសមាជិកសភាម៉ាឡេស៊ី បានថ្លែងថា "ការអនុម័តសេចក្តីស្នើច្បាប់នេះ នឹងបង្ហាញអំពីការស្លាប់នៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ យើងកំពុងនិយាយអំពីការផ្លាស់ប្តូរ ដែលនឹងប្រែក្លាយប្រទេសនេះ ទៅជារដ្ឋដែលមានគណបក្សតែមួយ ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ភាពស្របច្បាប់នៃការបោះឆ្នោត ដែលនឹងមកដល់នាប៉ុន្មានខែខាងមុខ។ ក្នុងនាមជាសមាជិកសភា វាពិតជាគួរឱ្យព្រួយបារម្ភណាស់ ដែលឃើញសេចក្តីស្នើច្បាប់មួយដែលគម្រាមកំហែងចំពោះដំណើរការប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យនៃស្ថាប័ននីតិប្បញ្ញត្តិ ត្រូវបានធ្វើឡើងយ៉ាងលឿន ដោយមិនបានផ្តល់ពេលគ្រប់គ្រាន់សម្រាប់ការពិភាក្សា ឬជជែកដេញដោល។ ដៃគូ និងរដ្ឋាភិបាលអន្តរជាតិ គួរធ្វើការថ្កោលទោសចំពោះការផ្លាស់ប្តូរនេះ និងទាមទារឱ្យគណបក្សប្រជាជនកម្ពុជា ធ្វើការកែប្រែគម្រោងការណ៍វិសោធនកម្មនេះ។

សេចក្តីស្នើច្បាប់នេះ ចែងអំពីការវិសោធនកម្មចំពោះច្បាប់ ស្តីពីគណបក្សនយោបាយ ដែលនឹងផ្តល់នូវអំណាចដែលធ្លាប់មានដល់ស្ថាប័នតុលាការ និងស្ថាប័ននីតិប្រតិបត្តិ ដើម្បីព្យួរ និងរំលាយគណបក្សនយោបាយ។ សេចក្តីព្រាង ដោយផ្អែកលើសេចក្តីកែប្រែដែលស្នើដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅដើមខែនេះ ត្រូវបានអនុម័តយល់ព្រមដោយគណៈកម្មការនីតិកម្ម នៃរដ្ឋសភាជាតិ កាលពីថ្ងៃទី១៤ ខែកុម្ភៈកន្លងទៅ និងត្រូវបានគ្រោងនឹងពិភាក្សា និងអនុម័ត នៅថ្ងៃច័ន្ទនេះ។

ក្នុងចំណោមសេចក្តីស្នើកែប្រែចំពោះច្បាប់នេះ រួមបញ្ចូលទាំងអនុប្រយោគថ្មី ដែលអនុញ្ញាតឱ្យតុលាការកំពូលធ្វើការរំលាយគណបក្សនយោបាយ និងរារាំងថ្នាក់ដឹកនាំគណបក្ស ពីសកម្មភាពនយោបាយ ដោយមូលហេតុរំលោភបំពានលើបម្រាមហាមឃាត់មួយចំនួន ដែលមានន័យមិនច្បាស់លាស់ ដូចជាការគំរាមកំហែងដល់ "ឯកភាពជាតិ" ឬ "សន្តិសុខនៃរដ្ឋ"។ សេចក្តីស្នើច្បាប់នេះ ក៏រួមបញ្ចូលផងដែរនូវបម្រាមហាមឃាត់ចំពោះបុគ្គល

ដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ មិនឱ្យកាន់តួនាទីក្នុងថ្នាក់ដឹកនាំគណបក្ស។ ការរឹតត្បិតនេះ ត្រូវបានមើលឃើញជាទូទៅថា មានបំណងសំដៅដល់គណបក្សសង្គ្រោះជាតិ ដែលបានទទួលរងនូវចំណាត់ការតុលាការដោយមានចរិតលក្ខណៈនយោបាយបន្តបន្ទាប់ ប្រឆាំងនឹងថ្នាក់ដឹកនាំកំពូលរបស់គណបក្សជាច្រើនរូប ដោយរំលោភបំពានដោយផ្ទាល់លើអភ័យឯកសិទ្ធិសភាដែលការពារដោយរដ្ឋធម្មនុញ្ញ។

ឯកឧត្តម Walden Bello សមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការសមាជិកសភាអាស៊ាន និងជាអតីតសមាជិកសភាហ្វីលីពីន បានថ្លែងថា "អ្វីដែលមិនគួរឱ្យកើតឡើងចំពោះករណីនេះ គឺខ្លឹមសារនៃច្បាប់នេះ ហាមឃាត់គណបក្សនយោបាយ មិនឱ្យធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស។ ប៉ុន្តែ នេះជាអ្វីដែលសេចក្តីស្នើច្បាប់នេះខ្លួនឯង គម្រាមនឹងធ្វើ។"

"មាត្រាច្បាប់ដែលស្នើឡើងនេះ ច្បាស់ណាស់មានការប្រកាន់បក្ខពួក និងមានបំណងសំដៅដោយផ្ទាល់ចំពោះគណបក្សប្រឆាំង ដែលជាផ្នែកមួយនៃការខិតខំក្នុងការកម្ទេចគណបក្សប្រឆាំង ដោយមិនបានពិចារណាអំពីផលប៉ះពាល់អវិជ្ជមានចំពោះប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យជាស្នូល។"

សមាជិកសភាក្នុងតំបន់ ក៏បានបញ្ជាក់បន្ថែមថា ការបោះឆ្នោតអនុម័តនៅថ្ងៃច័ន្ទនេះ ព្រមទាំងការបន្តវាយប្រហារទៅលើសមាជិកសភាមកពីគណបក្សប្រឆាំងនៅក្នុងប្រទេសកម្ពុជា អាចនឹងបង្កឱ្យមានផលប៉ះពាល់ដល់តំបន់។

ឯកឧត្តម Charles Santiago ថ្លែងថា "អ្វីដែលកំពុងកើតមានក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន គឺជាសូចនាករដំបូងនៃការវាយប្រហារចំពោះលទ្ធិប្រជាធិបតេយ្យក្នុងតំបន់ទាំងមូល។ យើងបានមើលឃើញការផ្លាស់ប្តូរស្រដៀងគ្នានេះដែរនៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសដទៃទៀត។ ប៉ុន្តែឥឡូវនេះ គណបក្សប្រជាជនកម្ពុជា បានយកការវាយប្រហារនេះទៅកម្រិតថ្មីមួយទាំងមូល។ យើងត្រូវតែឈរនៅជាមួយបងប្អូនប្រុសស្រីកម្ពុជារបស់យើង ដែលកំពុងធ្វើការដើម្បីការពារគោលការណ៍ប្រជាធិបតេយ្យ ដោយប្រឈមនឹងការឃាយីដែលមិនធ្លាប់មានពីមុន។"